ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

## ស្តីពី

## លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំឆ្នាំ២០២០

នៅក្នុងឆ្នាំ២០២០នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ៖

**១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១-សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន ៖**

-បំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន២លើក

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ**

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន១០លើក សម័យប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន៥លើក។

**ខ-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ និងអន្តរជាតិ**

-អនុញ្ញាតឱ្យថ្នាក់ដឹកនាំប្រទេសជាមិត្ត គណៈប្រតិភូជាន់ខ្ពស់ជាតិ អន្តរជាតិ និងអង្គទូតនានា ចូលជួបជូនសារតាំង សម្តែងការគួរសម សវនាការ និងជម្រាបលា ចំនួន១៦លើក។

**គ-សកម្មភាពចុះមូលដ្ឋាន**

-អញ្ជើញចុះមូលដ្ឋាននៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា ចំនួន២៥លើក។

**ឃ-សកម្មភាពចូលរួមពិធីផ្សេងៗ**

-អញ្ជើញជាគណៈអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ ចំនួន ៣៧លើក។

**ង-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានចុះហត្ថលេខាលើព្រះរាជក្រមចំនួន៨ច្បាប់

-បានចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន២១៣ច្បាប់

-បានទទួលព្រះរាជសារព្រះរាជទានសិទ្ធិចំនួន១៧៦ច្បាប់

-បានទទួលសំណើពីរាជរដ្ឋាភិបាលចំនួន១៧១ច្បាប់

-បានទទួលសំណើពីរដ្ឋសភាចំនួន២៣ច្បាប់

-បានទទួលសំណើប្រមុខរដ្ឋស្តីទីចំនួន២ច្បាប់

-បានផ្តល់យោបល់ និងចុះហត្ថលេខាលើលិខិតផ្សេងៗចំនួន៣៣២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២៨០ច្បាប់។

**១.២-ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា អនុប្រធានទី១ ព្រឹទ្ធសភា បាន ៖**

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភា ចំនួន២លើក។

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ**

-អញ្ជើញដឹកនាំ និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន១៨លើក សម័យប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន១០លើក

-អញ្ជើញចូលរួមសិក្ខាសាលា និងកិច្ចប្រជុំនានាចំនួន៩លើក។

**ខ-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ និងអន្តរជាតិ**

-បានអនុញ្ញាតឱ្យឯកឧត្តម **យង់ ពៅ** អគ្គលេខាធិការរាជបណ្ឌិត្យសភាកម្ពុជា តំណាងឯកឧត្តមបណ្ឌិត្យសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា និងក្រុមការងារចូលជួបសម្តាសន៍ ដើម្បីរៀបចំគុណកថាលម្អិតសម្រាប់ពិធីប្រកាសគោរមងារកិត្តិយសដែល**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ត្រាស់បង្គាប់គោរមងារកិត្តិយសនៃរាជបណ្ឌិត្យសភាកម្ពុជា ជា "កិត្តិនីតិកោសលបណ្ឌិត"។

**គ-សកម្មភាពចូលរួមក្នុងពិធីផ្សេងៗ**

-អញ្ជើញជាគណៈអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ ចំនួន១៣លើក។

**ឃ-សកម្មភាពចុះមូលដ្ឋាន**

-អញ្ជើញចុះមូលដ្ឋាននៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា ចំនួន១០លើក។

**ង-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៧៩ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន៣៦៨ច្បាប់។

**១.៣-ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន ៖**

ក-សកម្មភាពចូលរួមកិច្ចប្រជុំ

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន១៨លើក និងសម័យប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន១០លើក។

**ខ-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ និងអន្តរជាតិ**

-អនុញ្ញាតឱ្យក្រុមការងាររាជបណ្ឌិត្យសភាកម្ពុជា ដឹកនាំដោយឯកឧត្តមបណ្ឌិត្យសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា និងជាអនុប្រធានប្រចាំការក្រុមប្រឹក្សាបណ្ឌិត្យសភាចារ្យធ្វើការសម្ភាស ដើម្បីរៀបចំគុណកថាលម្អិតសម្រាប់ពិធីប្រកាសគោរមងារកិត្តិយសដែល **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់សព្វព្រះរាជហឫទ័យត្រាស់បង្គាប់ផ្តល់គោរមងារកិត្តិយសនៃរាជបណ្ឌិត្យសភាកម្ពុជា ជា "កិត្តិសង្គហបណ្ឌិត"។

**គ-សកម្មភាពចុះមូលដ្ឋាន**

-អញ្ជើញចុះមូលដ្ឋាននៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុង ចំនួន១៣លើក។

**ឃ-សកម្មភាពចូលរួមក្នុងពិធីផ្សេងៗ**

-អញ្ជើញជាអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗចំនួន២៦លើក។

**ង-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៥៩ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន១៦៨ច្បាប់។

**២-សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍**

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានបើកសម័យប្រជុំចំនួន១៨លើក ដែលមានរបៀបវារៈដូចខាងក្រោម៖

១.ពិនិត្យ និងសម្រេចលើសេចក្តីព្រាងច្បាប់ចំនួន៣៦ច្បាប់

២.ការធ្វើវិចារណកម្មថវិកាព្រឹទ្ធសភា ក្នុងក្របខ័ណ្ឌច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ចំនួន២លើក

៣.ពិនិត្យ និងសម្រេចអំពីរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឱ្យស្របនឹងតម្រូវការថ្មីរបស់ស្ថាប័ន។

**៣.សម័យប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ**

ព្រឹទ្ធសភាបានបើកសម័យប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញចំនួន១០លើក ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន៣៦ច្បាប់។

## ៤-សកម្មភាពចូលរួមប្រយុទ្ធនឹងគ្រោះមហន្តរាយ

ថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបរិច្ចាគថវិកាផ្ទាល់ខ្លួន ប្រាក់បៀវត្សផ្ទាល់ខ្លួន ក្នុងការរួមចំណែកជាមួយរាជរដ្ឋាភិបាល ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងត្រៀមទិញវ៉ាក់សាំងកូវីដ-១៩ សម្រាប់ចាក់ជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ ព្រមទាំងបានចុះអប់រំផ្សព្វផ្សាយស្តីពី វិធានការការពារ និងទប់ស្កាត់ការរីករាលដាល នៃជំងឺកូវីដ-១៩ ជាពិសេស បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខ និងនាំយកអំណោយចែកជូនប្រជាពលរដ្ឋដែលទទួលរងគ្រោះដោយសារជំនន់ទឹកភ្លៀង។

## ៥-គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយឆន្ទៈ និងស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ៥.១-មុខងារនីតិកម្ម

គណៈកម្មការជំនាញព្រឹទ្ធសភាបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា ជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន៣៦ច្បាប់។

### ៥.២-មុខងារតាមដានការអនុវត្តច្បាប់

-អញ្ជើញជួបពិភាក្សាការងារជាមួយរដ្ឋមន្ត្រីក្រសួងទេសចរណ៍, រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា, ក្រុមសមាគមអ្នកចិញ្ចឹមសត្វកម្ពុជា, ប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ និងអគ្គនាយកដ្ឋានលំនៅដ្ឋាន នៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដើម្បីឈ្វេងយល់អំពីការរីកចម្រើនថ្មីៗ បញ្ហាប្រឈម វិធានការនានា និងស្តាប់របាយការណ៍លទ្ធផលការងារសម្រេចបានឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០

-អញ្ជើញចុះបេសកកម្ម ដើម្បីឈ្វេងយល់អំពី(១).ការអភិវឌ្ឍប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិក្នុងបុព្វបទថ្មី ពិសេសការងារចាត់តាំង ការអនុវត្តថវិកា ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈ (២).ពិនិត្យស្ថានភាពជាក់ស្តែងរបស់ឃុំ និងពិភាក្សាដោះស្រាយទំនាស់ដីធ្លីជូនប្រជាពលរដ្ឋ (៣).ការអភិវឌ្ឍផ្លូវថ្នល់ ផ្លូវដែក កំពង់ផែទឹកជ្រៅ និងដំណើរការរោងចក្រផលិតថាមពលអគ្គិសនីដុតធ្យូងថ្ម (៤).ការ

អនុវត្តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ(៥).ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងការអភិវឌ្ឍមូលដ្ឋាន (៦).ការវិវត្តរីកចម្រើនថ្មី និងបញ្ហាប្រឈមរបស់ខេត្ត (៧).ការផ្សព្វផ្សាយច្បាប់ (៨).ការអនុវត្តច្បាប់ និងដោះស្រាយពាក្យបណ្តឹង (៩).ការប្រមូលព័ត៌មានតាមវិស័យ (១០).ការអនុវត្តកំណែទម្រង់វិមជ្ឈការ (១១).ការគ្រប់គ្រងច្រកទ្វារអន្តរជាតិ (១២).ការផ្សព្វផ្សាយអំពីតួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា និងសិក្សាឈ្វេងយល់អំពីបញ្ហាប្រឈម ព្រមទាំងសំណូមពររបស់អាជ្ញាធរមូលដ្ឋាន ក្រុមប្រឹក្សាឃុំសង្កាត់ (១៣).វឌ្ឍនភាពនៃសមាហរណកម្មការិយាល័យជំនាញទៅក្នុងរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលក្រុង ស្រុក ការអនុវត្តថវិកា និងការអភិវឌ្ឍមូលដ្ឋាន នៅខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តតាកែវ ខេត្តកំពត ខេត្តកែប ខេត្តព្រះសីហនុ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តពោធិ៍សាត់ ខេត្តប៉ៃលិន ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តព្រះវិហារ។

**៥.៣-មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងចំនួន៧២ករណី បានធ្វើលិខិតអន្តរាគមន៍បញ្ជូនពាក្យបណ្តឹងទៅអាជ្ញាធរខេត្ត និងក្រសួងស្ថាប័នមានសមត្ថកិច្ចពិនិត្យដោះស្រាយចំនួន៥៦ករណី តម្កល់ទុកមិនចាត់ការចំនួន៨ករណី ដោះស្រាយបញ្ចប់ចំនួន១ករណី ទទួលលិខិតឆ្លើយតបពីលទ្ធផលនៃការដោះស្រាយពាក្យបណ្តឹងរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធចំនួន១៨ករណី បានឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន៥៨ករណី និងទទួលឯកសារពាក្យបណ្តឹងដែលក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការ ដើម្បីជូនជ្រាបជាព័ត៌មានចំនួន៥៣ករណី

-បានប្រជុំផ្សព្វផ្សាយអំពីស្មារតី នៃកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាស្តីពី ការធ្វើវិចារណកម្មថវិកាព្រឹទ្ធសភាចំនួន២លើក ក្នុងក្របខ័ណ្ឌច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០

-បានរៀបចំវេទិកាសាធារណៈថ្នាក់ខេត្តចំនួន៥លើកស្តីពី (១).ការពង្រឹងសមត្ថភាពសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ ក្នុងការរៀបចំថវិកា និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព (២).ការអនុវត្តតួនាទី ភារកិច្ចក្រុមប្រឹក្សាឃុំ និងសហការផ្តល់សេវាសាធារណៈ ព្រមទាំងការអភិវឌ្ឍមូលដ្ឋាន

(៣).ការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សា ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអភិវឌ្ឍមូលដ្ឋាន (៤).ការអភិវឌ្ឍមូលដ្ឋានធានាបាននូវការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និង(៥).តម្រូវការសេវាសង្គមនៅក្នុងមូលដ្ឋាន នៅរាជធានីភ្នំពេញ ខេត្តមណ្ឌលគិរី ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ

-បានជួបសំណេះសំណាល និងដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់សមាគមបេសកកម្មសិក្សាអាស៊ី (AMSA) ប្រទេសបារាំង និងក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មមនុស្សធម៌នៅកម្ពុជារបស់ប្រទេសបារាំង ចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបពិភាក្សាការងារជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ សំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ និងផ្សព្វផ្សាយវិធីបង្ការ និងទប់ស្កាត់ជំងឺកូវីដ-១៩ ដល់ប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តក្រុងនានាចំនួន៩៩៣លើក។

## ៥.៤-កិច្ចសហប្រតិបត្តិការអន្តរជាតិ

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំអន្តរជាតិនានាតាមប្រព័ន្ធវីដេអូ រួមមាន៖ (១).សន្និបាតវិសាមញ្ញរបស់ក្រុមប្រឹក្សាភិបាលសហភាពអន្តរសភា (IPU) លើកទី២០៦ (២).មហាសន្និបាតអន្តរសភាអាស៊ាន(AIPA) លើកទី៤១ (៣).មហាសន្និបាតប្រចាំឆ្នាំនៃបណ្តាញក្រុមសីលធម៌សភាប្រើភាសាបារាំង(៤).កិច្ចប្រជុំប្រចាំឆ្នាំលើកទី១១របស់ក្រុមអ្នកនយោបាយអាយប៉ា(11-AIPA Caucus) (៥).កិច្ចប្រជុំស្តីពីការផ្ទុះឡើងនៃជំងឺរីករាលដាល និងវិធានការបង្ការជំងឺកូវីដ-១៩ របស់មហាសន្និបាតសភាតំបន់អាស៊ី(APA) (៦).កិច្ចប្រជុំគណៈកម្មការអប់រំ ប្រាស្រ័យឆ្លើយឆ្លង និងកិច្ចការវប្បធម៌នៃសភាប្រើភាសាបារាំង (៧).កិច្ចប្រជុំពិសេសពាក់-

ព័ន្ធនឹងបណ្តាញស្ត្រីសភាប្រើភាសាបារាំង (៨).កិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង (៩).កិច្ចប្រជុំលើកទី១ នៃក្រុមការងារស្តីពី គោលនយោបាយដើម្បីបង្ការ និងគ្រប់គ្រងទប់ស្កាត់លើការបៀតបៀនផ្លូវចិត្ត និងផ្លូវភេទក្នុងសភាបារាំង និង(១០).សិក្ខាសាលាស្តីពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ ចំពោះការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)

សមាជិក សមាជិកាព្រឹទ្ធសភា បានអនុញ្ញាតឱ្យគណៈប្រតិភូជាន់ខ្ពស់ជាតិអន្តរជាតិចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ រួមមាន៖ ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋគុយបា, ឯកអគ្គរាជទូតតែងតាំងថ្មី នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេសបារាំង, នាយកសាលាសម្ព័ន្ធភាពបារាំង, នាយកគ្រប់គ្រងទូទៅCambodia Co.LTD, គណៈប្រតិភូកូរ៉េតំណាងក្រុមហ៊ុនHYUNDIA, គណៈប្រតិភូសាធារណរដ្ឋប្រជាមានិតចិន, អ្នកពិគ្រោះយោបល់ និងមន្ត្រីសម្របសម្រួលក្រុមការងាររបស់វិទ្យាស្ថានសភាកម្ពុជា។

ថ្ងៃអង្គារ ៧រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**កិត្តិសង្គហបណ្ឌិត ទេព ងន**

*ចម្លងជូន:*

- *ក្រសួងព្រះបរមរាជវាំង*
- *ក្រុមប្រឹក្សាធម្មនុញ្ញ*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *ក្រសួងយុត្តិធម៌*
- *ក្រសួងព័ត៌មាន*
- *(ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)*
- *កាលប្បវត្តិ-ឯកសារ*